## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៩ ខែមិនា ឆ្នាំ២០១៥

## ជប៉ុនផ្តល់៥៦៦,៧៤៥ ដុល្លារអាមេរិកសម្រាប់លើកកម្ពស់ការអប់រំបញ្ចូលគ្នា និងការអប់រំផ្នែកអនាម័យនៅកម្ពុជា



ក្រោមគ្រោងការណ៍នៃជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន ផ្តល់ថវិកាចំនួន២៧០,៨៨៦ដុល្លារអាមេរិក ដល់អង្គការសមាគមជន់សម្រាប់ជំនួយ និងសង្គ្រោះនៃប្រទេសជប៉ុន (AAR) និងផ្តល់ថវិកាចំនួន២៩៥,៨៥៩ដុល្លារអាមេរិក ដល់អង្គការ Japan Team of Young Human Power (JHP)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា កញ្ញា សូណូដា តូម៉ូកូ នាយិកាអង្គការAAR ដើម្បីអនុវត្ត "គម្រោងលើកកម្ពស់ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការនៅខេត្តកណ្តាល" និងកញ្ញា យ៉ាកាបេ សាគី អ្នកសម្របសម្រួល នៃអង្គការJHP ដើម្បីអនុវត្ត"គម្រោងសាងសង់អគារសិក្សា និងបង្គន់អនាម័យ ប្រព័ន្ធទឹកស្អាត និងទ្រទ្រង់អប់រំអនាម័យ សម្រាប់ធ្វើអោយប្រសើរឡើងនូវបរិស្ថានអប់រំនៅក្នុងសាលារៀន" នៅស្ថានទូតជប៉ុន។



សម្រាប់គម្រោងទីមួយ អង្គការAAR នឹងជួយលើកកម្ពស់ការអប់រំបញ្ចូលគ្នា តាមរយៈការបង្កើតអោយមានជម្រាលសម្រាប់កុមារពិការនៅក្នុងបរិស្ថានសាលារៀន និងការរៀបចំអោយមានការបណ្តុះបណ្តាលគ្រូបង្រៀនកុមារពិការ នៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ ព្រមទាំងប្រជាសហគមន៍ប្រមាណជា ៣,៨០០នាក់ នឹងទទួលបានចំណេះដឹងអំពីពិការភាព ហើយគម្រោងនេះ រំពឹងថា នឹងនាំអោយអត្រានៃការចុះឈ្មោះចូលរៀនរបស់កុមារពិការមានចំនួនកើនឡើង។



សម្រាប់គម្រោងទីពីរ អង្គការJHP នឹងធ្វើការសាងសង់អគារសិក្សាចំនួន៣កន្លែង រួមជាមួយនិងបរិក្ខាអនាម័យ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងរៀបចំសិក្ខាសាលា ក៏ដូចជាការបណ្តុះបណ្តាលនានា ដើម្បីពង្រីកចំណេះដឹងផ្នែកអនាម័យដល់សិស្សានុសិស្សប្រមាណជា ១,៣០០នាក់ និង លោកគ្រូអ្នកគ្រូ។ ជាមួយនិងគម្រោងនេះ បរិស្ថាននៅក្នុងសាលារៀន នឹងត្រូវបានកែលម្អហើយ និងទាក់ទាញសិស្សានុសិស្សកាន់តែច្រើនអោយមកចុះឈ្មោះចូលរៀនបន្ថែមទៀត។

កម្មវិធីជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មករដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង២២.៩លានដុល្លាអាមេរិក ដល់គម្រោងចំនួន៨៤គម្រោង ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី៧ តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៤របស់ជប៉ុន(មេសា២០១៤ ដល់មិនា២០១៥)។






ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp